ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន៖

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីទៀងរាល់សប្ដាហ៍

មាតិកា

I- ទីស្ដីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

១១-១-១៩៩៥ - អនុក្រឹត្យលេខ ០៥ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥០

១២-១-១៩៩៥ -អនុក្រឹត្យលេខ ០៦ អនក្រ ស្ដីពីការកែសំរួលផ្នែកយោធាតំបន់ជាការិយាល័យ
យោធាតំបន់ ៥១

៩-១-១៩៩៥ -អនុក្រឹត្យលេខ ០២ អនក្រ ស្ដីពីការតែងតាំងមន្ត្រីរាជការ ៥២

៩-១-១៩៩៥ -អនុក្រឹត្យលេខ ០៣ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៣

២.សេចក្ដីសំរេច

១៣-១-១៩៩៥ -សេចក្ដីសំរេចលេខ ០៦ សសរ ស្ដីពីការបង្កើតក្រុមប្រតិបត្តិការពិសេសរាប់ចំនួន
មន្ត្រី បុគ្គលិក រាជការស៊ីវិលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ៥៤

១៤-១-១៩៩៥ -សេចក្ដីសំរេចលេខ ០៧ សសរ ស្ដីពីការបញ្ចូលក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ៥៧

០៥-១-១៩៩៥ -សេចក្ដីសំរេចលេខ ០៨ សសរ ស្ដីពីការបន្ថែមសមាសភាពក្នុងគណៈកម្មការ
អន្តរក្រសួងសំរាប់បង្ការទប់ស្កាត់ និង បន្ថយជម្ងឺអេដស៍ និង កាមរោគ ៥៨

II- ការងារបណ្ដាក្រសួង

១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរ

១៤-១-១៩៩៥ - សារាចរលេខ ០០៣ សរ.សហវ.ទរ ស្ដីពីការធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ
(ដីធ្លី និង អាគារ) ៥៩

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សេចក្តីសំរេច

១៣-១-១៩៩៥ -សេចក្តីសំរេចលេខ ២៦៧ កបទសអ.ច្ប ស្តីពីការបង្កើត TASK FORCE របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សំរាប់សិក្សាស្រាវជ្រាវ បញ្ហាព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ៦១

២.ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

១៣-១-១៩៩៥ -ប្រកាសលេខ ០១២ ប្រក កសក-ចត ស្តីពីការតែងតាំងសាស្រ្តាចារ្យ គ្រូបង្រៀន ប្រចាំ សកលវិទ្យាល័យភូមិន្ទកសិកម្ម ឆ្នាំ ១៩៩៥ ....

៣.ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

១២-១-១៩៩៥ -ប្រកាសលេខ ១១/៩៥ កធស ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ៦៧

១២-១-១៩៩៥ -ប្រកាសលេខ ១២/៩៥ កធស ស្តីពីការលុបឈ្មោះអន្ត្រីរាជការ ៦៨

I- ទីស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៥ អនក្រ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើត និង ការប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

- បានឃើញគុណបំណាច់របស់សប្បុរសជន ក្នុងការរួមចំណែកសង្គ្រោះប្រជារាស្ត្រដែលទទួលរងគ្រោះធម្មជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ជូនចំពោះលោក **ទិញ ហួរ** ប្រធានក្រុមហ៊ុនបារីអង្គរ និងអាស៊ីអានអន្តរជាតិ ដែលបានបរិច្ចាគសម្ភារៈ និងប្រាក់សំរាប់ជួយដល់ប្រជារាស្ត្រដែលទទួលរងគ្រោះធម្មជាតិដូចមានចំនួនខាងក្រោម ÷

- ម៉ាស៊ីនបូមទឹក ១៥ សេះ ចំនួន ០៣ គ្រឿង
- បារីលុចសារី ចំនួន ២៥០ ស៊ុង
- ទឹកប្រាក់ ១.០០០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៦ អនក្រ
ស្តីពីការកែសំរួលផ្នែក យោធាតំបន់ ជា ការិយាល័យយោធាតំបន់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិ កម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានកែសំរួល ផ្នែកយោធាតំបន់ របស់ការិយាល័យទី ៥ ជាការិយាល័យ យោធាតំបន់ និងស្ថិតនៅក្រោមការបញ្ជាផ្ទាល់ របស់អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០២ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្តូរឋានៈសម្ព័ន្ធរដ្ឋបាលក្រុងកែបពី-ថ្នាក់ស្រុកមកជាថ្នាក់ក្រុង
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៤

សំរេច

មាត្រា ១ : តែងតាំងជាអភិបាលរងទី ២ និងទី ៣ ក្រុងកែប នូវអស់លោកដូចមានរាយនាមខាងក្រោម :

១_លោក **ជី ហួត** ជាអភិបាលរងទី ២ ក្រុងកែប

២_លោក **នេក ហួន** ជាអភិបាលរងទី ៣ ក្រុងកែប

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងអស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ខាងលើត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៣ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង មេដាយការងារជាតិ
- តាមសំណើរបស់អភិបាលនៃសាលារាជធានីភ្នំពេញ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនចំពោះក្រុមហ៊ុនអាជីវកម្ម និង សប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគថវិកាចូលរួមជួយកសាង និង កែលំអសោភ័ណភាពរាជធានីភ្នំពេញ ដូចមានរាយនាមតាមលំដាប់ថ្នាក់ខាងក្រោមនេះ ÷

ក.មេដាយស្ថាបនាជាតិថ្នាក់លេខ ១ :

១_ក្រុមហ៊ុន CENTURY GROUP កសាងសួនច្បារនៅមុខផ្សារពោធិចិនតុងចាស់អស់ ទឹកប្រាក់ ៥៥.០០០ ដុល្លារអាមេរិក

ខ.មេដាយស្ថាបនាជាតិថ្នាក់លេខ ២ :

១_ក្រុមហ៊ុន VONROLL ប្រទេសស្វីសផ្តល់បំពង់ទឹក ៥០០ ម៉ែត្រ មានតំលៃ ៧.៦៣៥ ដុល្លារអាមេរិក

២_សមាគម ពាណិជ្ជករកម្ពុជា ផ្តល់ប្រាក់ ៥.០០០ ដុល្លារអាមេរិក សំរាប់ទិញតុកៅអីសិស្ស

គ.មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ :

១_លោក លុន កុន ប្រធានសណ្ឋាគារអេរកត ផ្តល់ប្រាក់ ៣.០០០ ដុល្លារអាមេរិក សំរាប់ជួសជុលផ្លូវ

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០៦ សសរ
ស្តីពីការបង្កើតក្រុមប្រតិបត្តិការពិសេសរាប់ចំនួនមន្ត្រី បុគ្គលិក រាជការ ស៊ីវិល នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល

-បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១ ប្រក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការកែទំរង់រដ្ឋបាលសាធារណៈ

- ផ្អែកតាមសភាពការណ៍ចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមប្រតិបត្តិការពិសេសរាប់ចំនួន មន្ត្រី បុគ្គលិក រាជការ ស៊ីវិល នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី និង រួមមានសមាសភាពដូចតទៅ ÷

១_ឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហ ប្រធាន

២_ឯកឧត្តម **វ៉េង សេរីវុឌ្ឍ** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុ ប្រធានអចិន្ត្រៃយ៍

៣_ឯកឧត្តម **ស៊ុំ ម៉ានិត** សហរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៤_ឯកឧត្តម **នូច កានុខ** សហរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៥_ឯកឧត្តម **[illegible]** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៦_ឯកឧត្តម **ប្រាក់ សុខ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

អនុប្រធានអចិន្ត្រៃយ៍

៧_លោកជំទាវ **ម៉ូ សុខួន** ទីប្រឹក្សាឯកឧត្តមសហរដ្ឋមន្ត្រីទី ២ អនុប្រធានអចិន្ត្រៃយ៍

៨_ឯកឧត្តម **ទេព ដារ៉ុង** ទីប្រឹក្សាឯកឧត្តម វ៉េង សេរីវុឌ្ឍ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩_ឯកឧត្តម **ជា ម៉េងឃាង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០_ឯកឧត្តម **កាន់ ស៊ិនតូ** អគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

១១_ឯកឧត្តម **សុខ សាលន់** ប្រធានមជ្ឈមណ្ឌលកុំព្យូទ័រទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២_លោក **នួន ស៊ីន** ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សមាជិក

១៣_លោក **អ៊ិក សណ្តាប់** អនុប្រធានខុទ្ទកាល័យក្រសួងសាធារណៈការ និងដឹកជញ្ជូន សមាជិក

១៤_លោក **អ៊ុំ ទិចទ្រីក** អនុប្រធានខុទ្ទកាល័យក្រសួងសុខាភិបាល សមាជិក

១៥_លោក **ឆយ អ៊ូយ** អនុប្រធាននាយកដ្ឋានក្រសួងអប់រំយុវជននិងកីឡា សមាជិក

ប្រការ ២ : ក្រុមប្រតិបត្តិការពិសេសរាប់ចំនួនមន្ត្រី បុគ្គលិក រាជការ ស៊ីវិល នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិនិងភារកិច្ចដូចតទៅ :

_រៀបចំគំរោងការ ដើម្បីដំណើរការរាប់ចំនួន មន្ត្រី បុគ្គលិក រាជការស៊ីវិល

_រៀបចំបែបបទ និង លក្ខខ័ណ្ឌ អំពីការរាប់ចំនួនមន្ត្រី បុគ្គលិក រាជាការស៊ីវិល

_ណែនាំការអនុវត្តន៍ និងអនុវត្តការរាប់ចំនួនមន្ត្រី បុគ្គលិក រាជការស៊ីវិល

_ចែក និងប្រមូលសលាកប័ត្រ

_ត្រួតពិនិត្យ សលាកប័ត្រ

_រ៉ូម៉ាំង កម្ម (Romanisation)

_បញ្ចូលកុំព្យូទ័រ

_គ្រោងថវិការបំរើការរាប់ចំនួនមន្ត្រី បុគ្គលិក រាជការស៊ីវិល

_ផ្តល់ផ្គង់សំភារៈបរិក្ខារ និងមធ្យោបាយក្នុងការដំណើរការរាប់ចំនួនមន្ត្រីបុគ្គលិករាជការស៊ីវិល

_រៀបចំ ឃ្លាំង រក្សាតំកល់សលាកប័ត្រ

_សហការជាមួយបណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ ដើម្បីដំណើរការរាប់ចំនួន មន្ត្រី បុគ្គលិករាជការស៊ីវិល

_ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល

ប្រការ ៣: ក្រុមប្រតិបត្តិការពិសេសរាប់ចំនួនមន្ត្រី បុគ្គលិក រាជការ ស៊ីវិល នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង មានសិទ្ធិបង្កើតលេខាធិការដ្ឋានរបស់ខ្លួន ដើម្បីដំណើរការកិច្ចការ ឱ្យមានប្រសិទ្ធភាព ។

ប្រការ ៤ : គ្រប់សមាជិកក្រុមប្រតិបត្តិការពិសេស រាប់ចំនួន មន្ត្រី បុគ្គលិក រាជការ ស៊ីវិល នៅទូទាំង ព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមប្រជុំ និង អនុវត្តការងារតាមការអញ្ជើញ និងការប្រគល់ភារកិច្ច របស់សហប្រធានក្រុម ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលមានការពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានឈ្មោះចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្ត សេចក្តីសំរេចនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ,ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០៧ សសរ
ស្តីពីការបញ្ចូលក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិល

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ

សំរេច

ប្រការ ១ : ត្រូវបានបញ្ចូលមន្ត្រី បុគ្គលិករដ្ឋបាលស៊ីវិល អតីតរចនាសម្ព័ន្ធរដ្ឋបាលភាគីរណសិរ្សជាតិ រំដោះប្រជាពលរដ្ឋខ្មែរ ចំនួន ៥.៤៨០ នាក់ (ប្រាំពាន់បួនរយប៉ែតសិបនាក់) ទៅក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលនៃរាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម ÷

១_ក្រសួងមហាផ្ទៃ	១.១៨៦ នាក់
២_ក្រសួងកសិកម្ម_រុក្ខាប្រមាញ់ និងនេសាទ	៣១៩ នាក់
៣_នាយកដ្ឋានគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	៧១ នាក់
៤_ក្រសួងពាណិជ្ជកម្ម	០២ នាក់

៥_ក្រសួង អប់រំយុវជន និងកីឡា ១.៧៦៧ នាក់

៦_ក្រសួងអភិវឌ្ឍន៍ជនបទ ៤៥៤ នាក់

៧_ក្រសួង សុខាភិបាល ១.០៨៩ នាក់

៨_ក្រសួងគ្រប់គ្រងបរិស្ថាន ០៥ នាក់

៩_ក្រសួង យុត្តិធម៌ និង តុលាការ ២៥២ នាក់

១០_ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ១៧០ នាក់

១១_ក្រសួង ពត៌មាន ១៤០ នាក់

១២_ក្រសួងទេសចរណ៍ ១៥ នាក់

១៣_ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០៥ នាក់

១៤_ក្រសួង សង្គមកិច្ច ការងារ និងអតីតយុទ្ធជន ០៥ នាក់

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រសួង រដ្ឋលេខាធិការដ្ឋាន លោកអភិបាលសាលាខេត្ត_ក្រុង មានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ,ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០៨ សសរ
ស្តីពីការបន្ថែមសមាសភាពក្នុងគណៈកម្មការអន្តរក្រសួង សំរាប់បង្ការទប់ស្កាត់ និងបន្ថយជម្ងឺអេដស៍ និងកាមរោគ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤

-យោងសេចក្តីសំរេចលេខ ៦៩ សសរ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត គណៈកម្មការអន្តរក្រសួង សំរាប់បង្ការទប់ស្កាត់ និងបន្ថយជម្ងឺអេដស៍ និងជម្ងឺកាមរោគ

-យោងតាមការងារចាំបាច់ចំពោះមុខ

សំរេច

ប្រការតែមួយគត់ : បន្ថែមសមាសភាពក្នុងប្រការ ១ នៃសេចក្តីសំរេចលេខ ៦៩ សសរ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលចំនួន ០២ រូបគឺ :

៨-ឯកឧត្តម **ស៊ុយ សែម** រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច ការងារ និង យុវជន ជាអនុប្រធាន

៩-ឯកឧត្តម **ឌីណារ៉ុឌរិទ្ធិ** រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល ជាអនុប្រធាន

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

-*-*-

II- ការងារបណ្តាក្រសួង

១. ធីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរ

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៥

សារាចរលេខ ០០៣ សរ.សហវ.ធរ
ស្តីការធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និង អាគារ)

កន្លងមកការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង ទើបតែអនុវត្តបានត្រឹមការកត់ត្រា ក្នុងបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំតែប៉ុណ្ណោះ ។ ទន្ទឹមនេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលបាននឹងកំពុងជំរុញយ៉ាងសកម្ម ក្នុងការពិនិត្យតាមដាននិងប្រមូលផ្តុំកត់ត្រានូវទ្រព្យសម្បត្តិរដ្ឋ ដើម្បីគ្រប់គ្រងអោយបានម៉ឺងម៉ាត់តាមផ្លូវច្បាប់ ។

ដើម្បីជៀសវាងនូវការបាត់បង់ទ្រព្យសម្បត្តិរដ្ឋដោយថាហេតុ និងក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលអោយរាជរដ្ឋាភិបាល គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ខេត្ត-ក្រុងនានា ដូចតទៅ ÷

១- ត្រូវចាត់តាំងធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និង អាគារ) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង ទោះបីជា ដីធ្លី និង អាគារមួយចំនួនដែលបានជួលអោយឯកជន ឬ ក្រុមហ៊ុន (ក្នុងស្រុក និង បរទេស) ក្តីដោយរាប់ទាំងអាគារសំណង់ ដែលបានជួសជុលនិងសាងសង់ កំពុងដំណើរការអាជីវកម្ម សេវាកម្មផង (ផ្អែមតាមកិច្ចសន្យាជួល និងកិច្ចសន្យាវិនិយោគដែលកំពុងអនុវត្ត) នោះជាបន្ទាន់ ។

២- ការិយាល័យភូមិបាលខេត្ត- ក្រុង ត្រូវរៀបចំធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ជូនដល់បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង អោយបានទាន់ពេលវេលា ។

៣- ក្រោយពេលបានរៀបចំធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និង អាគារ) រួចរាល់ហើយ ក្រសួង រដ្ឋលេខាធិការ ស្ថាប័ន ខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ញើបណ្តាឯកសារនៃកម្មសិទ្ធិទាំងនោះ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយបានមុនថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥ ជាកំណត់ ។

ក្រោយពេលទទួលបាននូវសារាចរនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង ត្រូវមានវិធានការអនុវត្ត ការធ្វើកម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី និង អាគារ) អោយមានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

***

២. ធីស្តីការរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៦៣ កបធសអ.ច្ប
ស្តីពីការបង្កើត TASK FORCE របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សំរាប់សិក្សាស្រាវជ្រាវបញ្ហាព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៤
-យោងតាមលិខិតទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១១៦៦ សជណ ជក នៃព្រះរាជាណាចក្រកម្ពុជា
-យោងតាម ការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើត TASK FORCE របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សំរាប់សិក្សាស្រាវជ្រាវបញ្ហាព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចតទៅ :

១_ឯកឧត្តម **អ៊ុច ស៊ាន**	អនុរដ្ឋលេខាធិការ	ប្រធាន
២_លោក **ឈ្នួង ផុល**	ប្រធាននាយកដ្ឋាន	អនុប្រធាន
៣_លោក **ស៊ុន សួន**	អនុប្រធាននាយកដ្ឋាន	អនុប្រធាន
៤_លោក **ឈ្នួង ចិសារលោ**		ទីប្រឹក្សា
៥_លោក **យឹម អ៊ី**		ទីប្រឹក្សា
៦_លោក **ប៉ុក សំអាន**		ទីប្រឹក្សា
៧_លោក **អ៊ាត លីហេង**	អនុប្រធាននាយកដ្ឋាន	សមាជិក
៨_លោក **ស៊ា កុសល**		សមាជិក
៩_លោក **កែច ភិក្សា**		សមាជិក
១០_លោក **ណៃ ម៉េងអ៊ាង**		សមាជិក

ក្រុម TASK FORCE មានលេខាធិការបីរូប ជាជំនួយការដែលមានសមាសភាពដូចតទៅ :

១_លោក **គួរ លិន្ទមុណី**

២_លោក **គីម សុវណ្ណា**

៣_លោក **អួន ណារ៉ុំ**

ប្រការ ២ : ក្រុម TASK FORCE មានភារកិច្ច :

- សៀវភៅសិក្សាស្រាវជ្រាវរាល់ឯកសារទាំងឡាយ ដែលពាក់ព័ន្ធបញ្ហាព្រំដែនគោក_សមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិ ។
- លើកមតិជាទស្សនៈយោបល់ ពីលទ្ធផលការងារនិងសំណូមពរផ្សេងៗ ជូនក្រសួងនិងគណៈកម្មការព្រំដែនអន្តរក្រសួង ពិនិត្យនិងសំរេច ។

ប្រការ ៣ : សមាជិក និង លេខាធិការ របស់ក្រុម TASK FORCE ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ឥស្សរជន និង មន្ត្រីផ្សេងៗទៀតដែលពាក់ព័ន្ធ ឬមានបទពិសោធន៍ ឬជំនាញក្នុងបញ្ហាព្រំដែន អាចត្រូវបានអញ្ជើញចូលរួមប្រជុំ ក្នុងក្របខ័ណ្ឌក្រុម TASK FORCE ។

ប្រការ ៤ : លោកនាយកខុទ្ទកាល័យរដ្ឋមន្ត្រី លោកប្រធាននាយកដ្ឋានកិច្ចការទូទៅ និងនាយកដ្ឋានទាំងអស់ក្រោមឱវាទក្រសួងនិងសាមីខ្លួនមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អ៊ុង ហួត

***

៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ ០១ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១២ ប្រក.កសក.ចក
ស្តីពីការតែងតាំង សាស្ត្រាចារ្យ គ្រូបង្រៀន
ប្រចាំ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ឆ្នាំ ១៩៩៥

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់ក្រសួងកសិកម្ម

_បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ ចុះថ្ងៃ ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីប្រាក់គំរៃបន្ថែមតុកោសល្យលើបៀវត្សជូនបុគ្គលិកសិក្សាគ្រប់ជាន់ថ្នាក់

_ តាមសំណើលេខ ៦៩៧ សវកក រចត ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៤ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

សំរេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន ១១០ នាក់ ឱ្យទទួល បន្ទុកជាសាស្ត្រា ចារ្យ គ្រូបង្រៀននិសិត្ស ដែលមានកំរិតថ្នាក់ឧត្តម មធ្យម និងបឋម ដូចមានរាយនាមខាងក្រោម :

ក.កំរិតឧត្តម ចំនួន ៣០ នាក់

១_ លោក ចាន់ ណារ៉េត
២_លោក ដាំ សំបូរ
៣_លោក ផាត់ មុនី
៤_ លោក ប៉ូរ៉ា គាធី
៥_លោក ជួង សុផល
៦_លោក សំ សារ៉ន
៧_លោក សុក គន្ធី
៨_លោកវ៉ង សេដ្ឋា
៩_លោក កង អួន
១០_លោក សេង សីហា
១១_លោក ឌុក ឆេង
១២_លោក គួយ សុផល
១៣_លោក ចាន់ សារុទ្ធ
១៤_លោក ង៉ោ ប៊ុនថាន
១៥_ លោក ទូន សុភាព
១៦_លោក ទូនវិចិត្រ
១៧_លោក សេន
១៨_លោក ងិន ឆាយ
១៩_លោក លីវ លាងហ៊ី
២០_លោក គុយ ហួត
២១_លោក ម៉ៅ សំអុនវុត្ថា
២២_លោក ប៉ែន សុផុន
២៣_លោក ស្រី ប៊ុនឌឿន
២៤_លោក ទូច គីមឆាន
២៥_លោក ម៉ៅ សុភារ៉េត
២៦_លោក ក ធីណារ៉ុថ
២៧_លោក មាស សុទ្ធី
២៨_លោក សេង វិទ្យា
២៩_លោក ប៊ុន លាងហេង
៣០_លោក ប៊ុល សុខា

៣១_ លោក ចៅ កិច
៣២_ លោក ឡាយ យ៉ុន
៣៣_ លោក ឡេង ប៊ុនហ៊ិ
៣៤_ លោក វ៉ន មុនិន្ទ
៣៥_ លោក សេង សំផល
៣៦_ លោក ឈួក បូរិន
៣៧_ លោក ចាយ ណារ៉ុច
៣៨_លោក ឡោ រស្មី
៣៩_លោក ឃួន អៀង
៤០_លោក សង់ ពលរិទ្ធ
៤១_លោក ឃី វិបុលបុត្រា
៤២_លោកស្រី ជិប ស៊ីណាត
៤៣_លោកស្រី រស់ សុភាវ៉ាឌី
៤៤_លោកស្រី សុខ សុផល
៤៥_លោកស្រី ញ៉ែម ថាវី
៤៦_លោកស្រី ពាន សុអា
៤៧_លោកស្រី ប៉ៅ សាប៊ិណា
៤៨_លោក សៀង ជារ៉ុង្គ
៤៩_លោក ខៃ សត្យា
៥០_លោក សុខ វ៉ាន់ថន
៥១_លោក ឡាំ ប៉ី
៥២_លោក ម៉ែន សុខា
៥៣_លោក ចាន់ រដ្ឋា
៥៤_លោក ហួត វុត្ថា
៥៥_លោក តែ គុយហោ
៥៦_លោក ប៊ុន ទៀន
៥៧_លោក អ៊ុន ប៊ុនលាង
៥៨_លោក ទូច វិសាលសុខ
៥៩_លោក ម៉ៅ ណារ៉ា
៦០_ លោក លឹម វណ្ណៈ
៦១_លោក សៀង ម៉េង
៦២_លោក ហេង សាម័យ
៦៣_លោក ហេង ចំរើន
៦៤_លោក តុប ពេជ្រ
៦៥_លោកឃុន សុផល
៦៦_លោក ផន រិទ្ធី
៦៧_លោក សួស ចំណាន
៦៨_លោក លឹម ហាំងគ្រី
៦៩_កញ្ញា ហ៊ិល ថារិន
៧០_អ្នកស្រី ពាន សុខុនណ្ឌារ៉ា

៦.ភិរកមធ្យម ចំនួន ៩ នាក់

១_លោក អ៊ុន ផល្លី
២_លោក អ៊ូ សាមឿន
៣_លោក ហ៊ុន ប៊ុនធឿន
៦_លោក ហួត តង់ហ៊ាង
៧_លោក អ៊ុល នទី
៨_លោក ហៀប អានរក្ស

៤-លោក ឈុម កុសល

៥-លោក ថៃ គិមសុង

៦-លោក គីម ពុធដារ៉ា

គ-កិរិកបម្រើចំនួន ៣១ នាក់

១-លោក ឈីន ឈីន

២-លោក សួស ជុំ

៣-លោក ស្រី សំណើត

៤-លោក ចាន់ សុង

៥-លោក ពេជ្រ សារី

៦-លោក មុ ចាន់ថន

៧-លោក ឡាង តាំងអួន

៨-លោក ស៊ិន ធឿន

៩-លោក ស៊ីម សំណាង

១០-លោក កែវ សុង

១១-លោក ចន ចាន់

១២-លោក ឆេង ពិសិដ្ឋ

១៣-លោក សុខ បូរមី

១៤-លោក គង់ ប៉េន

១៥-លោក អ៊ួន សុផល

១៦-លោក មុំ ហូ

១៧-លោក សំ គិមហេង

១៨-លោក ព្រឿង ព្រិន

១៩-លោក សៀង ចាន់សយ

២០-លោក មិុច សុខុម

២១-លោកស្រី វៀល សុខា

២២-លោកស្រី នេត សារ៉ុន

២៣-លោកស្រី ស៊ិន សមណា

២៤-លោកស្រី គីម ច័ន្ទបូរ

២៥-លោកស្រី ឈាង អាំងគ្រី

២៦-លោកស្រី អ៊ិន ផល្លា

២៧-លោកស្រី ប៊ុញ ចន្ថា

២៨-លោក អ៊ុម រិន

២៩-កញ្ញា នុត ចន្ថា

៣០-កញ្ញា ដាំ សុខុម

៣១-កញ្ញា ប៉ោក សារី

មាត្រា ២ : សាស្ត្រាចារ្យ-គ្រូចំនួន ១១០ នាក់ ត្រូវបានទទួលប្រាក់កំរៃកោរ្យកោសល្យ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ ។

មាត្រា ៣ : ប្រកាសមុនៗ ដែលពាក់ព័ន្ធនិងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : ប្រធានមន្ទីរ ,ប្រធាននាយកដ្ឋាន ចាត់តាំង_បុគ្គលិក ,ប្រធាននាយកដ្ឋាន ផែនការ_ស្ថិតិ ,ប្រធាននាយកដ្ឋានគណនេយ្យ_ហិរញ្ញវត្ថុ ,សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាមីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាន់ សាផាន

***

៤- ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១/៩៥ ក.ធ.ស

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣

-បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃ ក្រសួងធម្មការ និង សាសនា ។

-បានឃើញលិខិតលេខ ២២៦ ៩៤ ម.ខ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ របស់មន្ទីរធម្មការ និង សាសនា ខេត្ត ស្ទឹងត្រែង ។

សំរេច

ប្រការ១ : លុបឈ្មោះអ្នកស្រី **ខាំ ផាន់** ចេញពីក្របខ័ណ្ឌមន្ទីរធម្មការនិងសាសនា ខេត្តស្ទឹងត្រែង

ប្រការ ២ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់អ្នកស្រី ខាំ ផាន់ ដាច់ផ្តាច់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ៗ របស់អ្នកស្រី ខាំ ផាន់ អាស្រ័យដោយមន្ទីរធម្មការ និង សាសនា ខេត្តស្ទឹង ត្រែង ជាអ្នករៀប ចំ ។

ប្រការ ៤ : មន្ទីរធម្មការ និង សាសនាខេត្ត មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្ត និងអ្នកស្រីដែលមានឈ្មោះក្នុង ប្រការ ១ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និង ត្រា

ហៀន ចណ្ណារិទ្ធ

***

រាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១២/៩៥ ក.ធ.ស
ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣

-បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយ ប្រើតាមក្រឹត្យ លេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃ ក្រសួងធម្មការ និង សាសនា ។

-បានឃើញលិខិតលេខ ៨៤-៩៤ ម.ធ.ស.ខ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់មន្ទីរធម្មការ និង សាសនា ខេត្ត កំពង់ស្ពឺ ។

បានឃើញពាក្យសុំលាឈប់ពីការងាររបស់លោកស្រី... ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៤

សំរេច

ប្រការ១ : លុបឈ្មោះលោក **លឹម ប៊ុនយ៉ាន** ចេញពីក្របខ័ណ្ឌមន្ទីធម្មការនិងសាសនា ខេត្តកំពង់ស្ពឺ

ប្រការ ២ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក លឹម ប៊ុនយ៉ាន ចាប់ផ្តាច់ពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ៗ មន្ទីរធម្មការ និង សាសនា ខេត្តកំពង់ស្ពឺជាអ្នករៀបចំស្នើឡើង ។

ប្រការ ៤ : មន្ទីរធម្មការ និង សាសនាខេត្ត មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្ត និងលោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និង ត្រា

ហៀន វណ្ណារិទ្ធ

បោះពុម្ពនៅរោងពុម្ពធីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៣៦៤ រៀល